**សុន្ទរកថា**

**របស់អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
**ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**ថ្លែងក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគាររដ្ឋបាល, អគារ សាលាជាតិគយ, និង សារមន្ទីរគយ នៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា**
**ថ្ងៃ ព្រហស្បតិ៍, ៤ រោច, ខែ មិគសិរ, ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥**
**រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ គ.ស. ២០២១**

- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជា-**ណាចក្រកម្ពុជា**ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត;
- សម្តេច, ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយស ជាទីគោរព និង ជាទីរាប់អាន!

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ, ក្នុងនាមមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមសំដែងនូវគារវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅបំផុត ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់ និង ឧត្តុង្គឧត្តមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋ-មន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ ខ្ញុំក៏សូមសម្តែងនូវអំណរគុណផងដែរ ចំពោះវត្តមានរបស់សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, តំណាងក្រសួង-ស្ថាប័នរបស់រាជរដ្ឋា-ភិបាល, ភ្ញៀវជាតិ និង អន្តរជាតិនានា ដែលបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាល, អគារសាលាជាតិគយ, និង សារមន្ទីរគយ នៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា នាថ្ងៃនេះ ។ អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ពិតជាញ៉ាំងឱ្យពិធីនេះ មានភាពអធិកអធម, មានន័យជាប្រវត្តិសាស្ត្រ, ហើយក៏ជាការផ្តល់កិត្តិយស

និង ជាការលើកទឹកចិត្តយ៉ាងកក់ក្ដៅ ដល់យើងខ្ញុំទាំងអស់គ្នា ជាមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, និង ជាពិសេស មន្ត្រីគយ និង រដ្ឋាករកម្ពុជា ។ ទន្ទឹមនឹងនេះ, វត្ត-មានដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** នាពេលនេះ ក៏បានឆ្លុះបញ្ចាំងផងដែរ នូវការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល មកលើរដ្ឋបាលគយ និង រដ្ឋាករកម្ពុជា ដែលបាន និង កំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការប្រមូលចំណូល ក៏ដូចជាការធ្វើឲ្យប្រសើរឡើង នូវបរិយាកាសវិនិយោគ និង កិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការចូលរួមអនុវត្តយ៉ាងសកម្ម នូវគោលនយោបាយ, យុទ្ធសាស្ត្រ និង កម្មវិធីកែទម្រង់មុតស្រួចនានា របស់រាជរដ្ឋាភិបាល ។

ដោយហេតុថា ថ្ងៃនេះ ជាថ្ងៃប្រវត្តិសាស្ត្រនៃការដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការ នូវអគាររដ្ឋបាលនៅទីចាត់ការកណ្ដាល, អគារសាលាជាតិគយ, និង សារមន្ទីរគយ, ហើយម្យ៉ាងទៀត, ពិធីនេះ ត្រូវបានប្រារព្ធឡើងក្នុងឆ្នាំដែលអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ទើបបានប្រារព្ធខួបអនុស្សាវរីយ៍ ៧០ ឆ្នាំ នៃការបង្កើតរដ្ឋបាលគយកម្ពុជា ២៩ មិថុនា ១៩៥១ - ២៩ មិថុនា ២០២១, ខ្ញុំសូមអនុញ្ញាតគោរពជម្រាបជូន **សម្ដេចតេជោ នាយករដ្ឋ-មន្ត្រី** និង អង្គពិធីទាំងមូល ដោយសង្ខេប អំពីសាវតាខ្លះៗ ពីអតីតកាល មុននឹងឈានដល់ការសម្រេចបាននូវសំណង់អគារដ៏ស្កឹមស្កៃទាំងនេះ, ហើយបន្ទាប់ពីនេះ, ខ្ញុំក៏នឹងគូសរំលេចអំពីលទ្ធផលការងារស្នូលនៃការប្រមូលចំណូលពន្ធ និង អាករ និង វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ និង កម្មវិធីការងារកែទម្រង់ និង ទំនើបកម្មរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ផងដែរ ។

- **សម្ដេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!**
- **សម្ដេច, ឯកឧត្ដម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយស!**

ក្នុងសម័យអាណានិគមបារាំង, រដ្ឋបាលគយ និង រដ្ឋាករកម្ពុជា ត្រូវបានបង្កើតឡើងក្នុងទម្រង់ជាទីចាត់ការរងមួយ (ជាភាសាបារាំងហៅថា Sous-Direction) នៅទីក្រុងភ្នំពេញ ឱ្យទទួលបន្ទុកគ្រប់គ្រងការងារគយ-រដ្ឋាករ នៅកម្ពុជា និង នៅឡាវភាគខាងត្បូង, ស្របគ្នានឹងទីចាត់ការរង ៣ ផ្សេងទៀត នៅក្នុងទូទាំងឥណ្ឌូចិន រួមមាន ៖ (១).ទីចាត់ការរងតុងកឹង នៅហៃហ្វុង (Haiphong); (២).ទីចាត់ការរងអាណ្ណាម នៅទូរ៉ាន-ដាណាង (Tou-rane-Danang); និង (៣).ទីចាត់ការរងកូសាំងស៊ីន នៅព្រៃនគរ (Saigon) ។ ទីចាត់ការរងទាំងបួននេះ ស្ថិតក្រោមការគ្រប់គ្រងរបស់ទីចាត់ការធំ នៃអគ្គទេសាភិបាលបារាំង នៅឥណ្ឌូចិន ដែលមានទីតាំងស្ថិតនៅទីក្រុងហាណូយ ។ អគារទីចាត់ការរងគយ-រដ្ឋាករកម្ពុជាដំបូងគេ ត្រូវ

បានសាងសង់អំពីឥដ្ឋ ស្ថិតនៅកណ្ដាលទីក្រុងភ្នំពេញ, ប៉ុន្តែ គួរឱ្យសោកស្ដាយដែលយើងពុំអាចស្វែងរកឯកសារបញ្ជាក់ពីអាសយដ្ឋានឱ្យបានច្បាស់លាស់ ដោយគ្រាន់តែដឹងថា ជាអកុសល, អគារនោះ ត្រូវបានអគ្គិភ័យឆាបឆេះខ្ទេចគ្មានសល់ ក្នុងអំឡុងខែ ឧសភា ឆ្នាំ ១៨៨៤ ។

បន្ទាប់មក, រដ្ឋបាលគយ និង រដ្ឋាករកម្ពុជា ក៏ត្រូវបានប្ដូរទៅអគារកំពស់ ៣ ជាន់, មានទីតាំងនៅតិវវិថីទន្លេសាប ដែលបច្ចុប្បន្នមានឈ្មោះថា តិវវិថីព្រះស៊ីសុវត្ថិ, ស្ថិតនៅសង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ។ ក្នុងឆ្នាំ ១៩៦៥, អគាររដ្ឋបាលនោះ ត្រូវបានវាយកម្ទេច និង ត្រូវបានសាងសង់ជំនួសមកវិញ នូវសណ្ឋាគារមួយ ដែលក្រោយមកមានឈ្មោះថា សណ្ឋាគារឆ្នេរទន្លេ ។ នៅឆ្នាំ ១៩៦៥ ដដែល, រដ្ឋបាលគយ និង រដ្ឋាករកម្ពុជា ត្រូវបានប្ដូរមកអគារដែលស្ថិតនៅទីតាំងបច្ចុប្បន្ន, ដែលពីមុន អគារនេះ ជាអតីតទីស្ដីការក្រសួងហិរញ្ញវត្ថុ ។

ក្រោយសម័យប៉ុលពត, រដ្ឋបាលគយ និង រដ្ឋាករកម្ពុជា បានចាប់ផ្ដើមដំណើរការឡើង-វិញ និង មានទីចាត់ការកណ្ដាល នៅអគារចំណាស់មួយជាន់, ដែលបច្ចុប្បន្នត្រូវបានកែលម្អជាសារមន្ទីរគយ, អមដោយអគារតូចៗដែលមានតែជាន់ផ្ទាល់ដី នៅជុំវិញអគារបុរាណនេះ ។ លុះដល់ឆ្នាំ ២០០១, ក្រោមការដឹកនាំរបស់ឯកឧត្ដម បណ្ឌិត **ប៉ែន ស៊ីម៉ន**, អគារតូចៗ ត្រូវបានរុះចេញ និង ជំនួសមកវិញ ដោយអគាររាងជាអក្សរ U មានកម្ពស់ ៤ ជាន់ ។

ក្រោមឧត្ដមមគ្គទេសក៍ និង ចក្ខុវិស័យដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេច-តេជោ នាយករដ្ឋមន្ត្រី** ដែលសម្ដេចបានដាក់ចេញ និង ដឹកនាំអនុវត្តប្រកបដោយជោគជ័យ នូវ **«នយោបាយឈ្នះ-ឈ្នះ»** និង ជាបន្តបន្ទាប់មកទៀត យុទ្ធសាស្ត្រត្រីកោណ, យុទ្ធសាស្ត្រចតុកោណ និង គោលនយោបាយកែទម្រង់មុតស្រួច និង ស៊ីជម្រៅលើគ្រប់វិស័យ, សេដ្ឋកិច្ច និង សង្គមកម្ពុជា ទទួលបានការអភិវឌ្ឍ និង រីកចម្រើនជាលំដាប់ ក៏ដូចជាការផ្លាស់ប្ដូរមុខ-មាត់ដ៏គួរជាទីមោទនៈ ។ ក្រោមម្លប់សន្តិភាពដ៏រឹងមាំ និង យូរអង្វែង, កំណើនសេដ្ឋកិច្ចខ្ពស់ជាប់មិនដាច់ ក្នុងចិរវេលាជិត ២ ទសវត្សរ៍, ដែលពុំធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជា, បាន និង កំពុងផ្ដល់ផលផ្លែផ្កា ដែលធ្វើឱ្យសមិទ្ធផលស្នានមិនដល់ជាច្រើន លេចចេញជារូបរាងឡើង ។ ជាក់ស្ដែង, នៅរាជធានីភ្នំពេញ, ដែលកាលពីមុន ពុំមានអគារខ្ពស់ៗសោះ, នៅពេលនេះ មានអគារច្រើនជាន់ និង ពហុមុខងារ កើតឡើងស្អេកស្កះ ដែលបាន និង កំពុងកែប្រែមុខមាត់រាជធានីរបស់យើងយ៉ាងឆាប់រហ័ស ។ យើងទាំងអស់គ្នា ពិតជាមានមោទន

ភាពខ្ពស់ ដែលអគាររដ្ឋបាលគយកម្ពស់ ៣៥ ជាន់នេះ ចូលរួមចំណែកក្នុងការបង្ហាញពីសមិទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាដែរ ។

ខ្ញុំសូមជម្រាបអង្គពិធីថា អគាររដ្ឋបាលគយនេះ ត្រូវបានចាប់ផ្តើមសាងសង់ ក្នុងខែ កុម្ភៈ ឆ្នាំ ២០១៧ និង បញ្ចប់ជាស្ថាពរ នៅខែ មេសា ឆ្នាំ ២០២០ ហើយត្រូវបានសម្ពោធប្រើ-ប្រាស់ជំហានដំបូង នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដោយដាក់ឲ្យប្រើប្រាស់ជាបឋមត្រឹម ១៨ ជាន់ប៉ុណ្ណោះ ។ បន្ទាប់ពីបញ្ចប់ការសាងសង់ជាស្ថាពរ, ដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩, យើងក៏ត្រូវបង្ខំចិត្តពន្យាការរៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ពេញលេញ ជាផ្លូវការ នូវអគាររដ្ឋបាលគយនេះ រហូតមកទល់បច្ចុប្បន្ន ។ ក្នុងខណៈដែលត្រូវរង់ចាំ, ការងារសាងសង់អគារសាលាជាតិគយ កម្ពស់ ១២ ជាន់, ដែលត្រូវបានចាប់ផ្តើម កាលពីខែ តុលា ឆ្នាំ ២០១៩, ក៏បានបញ្ចប់រួចរាល់ នាខែ វិច្ឆិកា ឆ្នាំ ២០២១, ហើយដំណាលគ្នា, អគារបុរាណ និង ជាប្រវត្តិសាស្ត្រតូចនេះ ក៏ត្រូវបានជួសជុលរួច និង រៀបចំប្រែក្លាយជាសារមន្ទីរគយផងដែរ ។ ប្រការនេះ បានផ្តល់ឱកាសឱ្យយើងរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវអគារទាំងអស់នេះរួមគ្នា ក្នុងពេលនេះតែម្តង ។

អគាររដ្ឋបាលគយ កម្ពស់ ៣៥ ជាន់នេះ មានការិយាល័យ, សាលប្រជុំ, អាហារដ្ឋាន, បន្ទប់ហាត់ប្រាណ និង ចំណតរថយន្ត ចំនួន ៨ ជាន់ (នៅក្រោមដី ២ ជាន់ និង លើដី ៦ ជាន់) ដែលបំពាក់ដោយឧបករណ៍ និង បរិក្ខារទំនើប ដូចជា ជណ្តើរយន្ត, ប្រព័ន្ធការពារអគ្គិ-ភ័យ, ប្រព័ន្ធគ្រប់គ្រងចំណតយានយន្ត, មជ្ឈមណ្ឌលទិន្នន័យបច្ចេកវិទ្យាព័ត៌មាននៃប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង ប្រព័ន្ធបញ្ជរតែមួយជាតិ ព្រមទាំងប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ ជាដើម ។

ចំពោះសាលាជាតិគយ, ដែលមានកម្ពស់ ១២ ជាន់, ត្រូវបានកសាងឡើងនៅលើផ្ទៃដីទំហំ ១ ហិចតា ក្នុងតំបន់អភិវឌ្ឍន៍ OCIC ជ្រោយចង្វារ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ផងដែរ ។ សាលាជាតិគយនេះ ក៏ត្រូវបានបំពាក់ដោយ សម្ភារៈបរិក្ខារទំនើបៗដូចគ្នាដែរ និង មានសាលប្រជុំតូច, សាលប្រជុំធំ, បណ្ណាល័យ, សាលសិក្សា, មន្ទីរពិសោធន៍, មណ្ឌលកីឡា, និង ភោជនីយដ្ឋាន ជាដើម ។ សាលាជាតិគយនេះ នឹងក្លាយជាមជ្ឈមណ្ឌលដ៏សំខាន់ សម្រាប់ការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេសគយ និង រដ្ឋាករ និង សម្រាប់ការចូលរួមចំណែកក្នុងការផ្លាស់ប្តូរបទពិសោធន៍ការងារជាមួយសាលាជាតិគយនៃប្រទេសផ្សេងទៀតក្នុងតំបន់ផងដែរ ។

ដោយឡែក, សារមន្ទីរគយ ត្រូវបានជួសជុល និង រៀបចំឡើង ដោយការអភិរក្សអគារ វ័យចំណាស់, មានលក្ខណៈជាប្រវត្តិសាស្ត្រ, ស្ថិតនៅខាងមុខជាប់នឹងអគាររដ្ឋបាលថ្មី ដើម្បីដាក់តាំងបង្ហាញនូវឯកសារ, កេរ្តិ៍ដំណែល, ស្នាដៃ, និង វត្ថុនានា ដែលទាក់ទងនឹងសាវតារ, តួនាទី, និង ភារកិច្ច របស់រដ្ឋបាលគយ និង រដ្ឋាករកម្ពុជា ក្នុងការងារប្រមូលចំណូល, កិច្ច-សម្រួលពាណិជ្ជកម្ម, និង ការបង្ការ និង បង្ក្រាបបទល្មើស ជាដើម ។ មន្ត្រីរាជការ, សាធារណ-ជនទូទៅ, ពិសេស សិស្ស និង និស្សិត, អាចសុំការអនុញ្ញាតចូលទស្សនា និង ធ្វើការសិក្សាស្រាវជ្រាវ នៅក្នុងសារមន្ទីរគយនេះបាន ដើម្បីស្វែងយល់, បង្កើននូវចំណេះដឹង, អំពីវិស័យគយ និង រដ្ឋាករកម្ពុជា ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ, ខ្ញុំសូមចូលរួមអបអរសាទរដល់មន្ត្រីគយ និង រដ្ឋាករទាំង-អស់ ដែលទទួលបាននូវចំណងដៃ ជាអគាររដ្ឋបាលដ៏ស្កឹមស្កៃ និង ថ្មីស្រឡាងទាំងនេះ ដែលជាសក្ខីភាពនៃការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាល, ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី,** លើការអភិវឌ្ឍស្ថាប័នគយ និង រដ្ឋាករកម្ពុជា ។

- សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!
- សម្តេច, ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយស!

បន្តទៅទៀតនេះ, ខ្ញុំសូមអនុញ្ញាតគូសរំលេចនូវសមិទ្ធផលការងារសំខាន់ៗមួយចំនួន ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សម្រេចបាននាពេលកន្លងមក គោរពជូន **សម្តេច-តេជោ នាយករដ្ឋមន្ត្រី** និង អង្គពិធីទាំងមូល ជ្រាបដូចខាងក្រោម ៖

### ទី១-ការងារប្រមូលចំណូល :

ខ្ញុំសូមអនុញ្ញាតរំលេចនូវលទ្ធផលចំណូលពន្ធ និង អាករ ប្រមូលដោយអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា នៅក្នុងឆ្នាំ ២០១៩ និង ក្នុងរយៈពេល ៥ ឆ្នាំ មុនកើតមានវិបត្តិកូវីដ-១៩ ដូចតទៅ : សម្រាប់ឆ្នាំ ២០១៩ ដែលជាឆ្នាំនៃការប្រមូលចំណូលបានល្អបំផុត, ចំណូលពន្ធ និង អាករ ប្រមូលដោយអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា សម្រេចបានក្នុងទំហំប្រមាណ ៣ ២១៤ លានដុល្លារអាមេរិក ត្រូវជា ១៤២,៣% នៃផែនការចំណូល កំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ។ បើគិតក្នុងរយៈពេល ៥ ឆ្នាំ, ពោលគឺពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៩, អត្រាកំណើនចំណូលពន្ធ និង អាករ ប្រមូលដោយអគ្គនាយក-

ផ្ទានគយ និង រដ្ឋាករកម្ពុជា មានជាមធ្យមប្រចាំឆ្នាំ ប្រមាណ ១៩.៥% ដែលធ្វើឱ្យតួលេខចំណូលឆ្នាំ ២០១៩ មានទំហំស្មើនឹងជិត ២ ដង នៃចំណូលដែលប្រមូលបាន នៅក្នុងឆ្នាំ ២០១៤ ។

ក៏ប៉ុន្តែ, ចាប់ពីដើមឆ្នាំ ២០២០ មក, ការរាតត្បាតនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរលើសេដ្ឋកិច្ចសកល រួមទាំងសេដ្ឋកិច្ចកម្ពុជាផងដែរ និង បានធ្វើឲ្យរង្គោះរង្គើរយ៉ាងខ្លាំងដល់ខ្សែច្រវាក់ផ្គត់ផ្គង់ពាណិជ្ជកម្មអន្តរជាតិ ។ កត្តានេះ បានធ្វើឲ្យចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ធ្លាក់ចុះគួរឲ្យកត់សម្គាល់ ។ ជាក់ស្តែង, ក្នុងឆ្នាំ ២០២០, ចំណូលពន្ធ និង អាករ ប្រមូលដោយអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា សម្រេចបានចំនួនតែ ៩ ៧៩៨,៤ ប៊ីលានរៀល គឺត្រូវជាប្រមាណ ៨៣.៥% នៃផែនការកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ។ នៅឆ្នាំ ២០២១ នេះ, ចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ត្រូវបានប៉ាន់ស្មានថា អាចសម្រេចបានប្រមាណជា ៩ ២៨៣ ប៊ីលានរៀល ឬ ត្រូវជា ៩៧% នៃផែនការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ។

### ទី២-ការងារសម្រួលពាណិជ្ជកម្ម :

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយ និង វិធានការនានារបស់រាជរដ្ឋាភិបាលសំដៅកែលម្អបរិយាកាសវិនិយោគ និង កិច្ចសម្រួលពាណិជ្ជកម្ម, អគ្គនាយកដ្ឋានគយ និង រដ្ឋា-ករកម្ពុជា បាន និង កំពុង អនុវត្តកម្មវិធីការងារជាអាទិភាពមួយចំនួន ជាអាទិ៍ ៖ (១). ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាក្នុងកិច្ចការគយ រួមមាន ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ, ប្រព័ន្ធបញ្ជរតែមួយជាតិ និង ប្រព័ន្ធគ្រប់គ្រងហានិភ័យគយ ជាដើម; (២). ការបន្តធ្វើសាមញ្ញកម្មនីតិវិធីគយ; (៣). ការបំពេញបែបបទគយមុនទំនិញមកដល់ (Pre-Arrival clearance) និង ការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ; (៤). ការផ្តល់ប្រព្រឹត្តិកម្មពិសេសដល់ធុរ-ជនមានអនុលោមភាពខ្ពស់ និង ការលើកកម្ពស់យន្តការពិគ្រោះយោបល់ជាមួយវិស័យឯក-ជន; និង (៥). ការពង្រឹងកិច្ចសហប្រតិបត្តិការគយអន្តរជាតិ, ទាំងក្នុងកម្រិតទ្វេភាគី និង ពហុភាគី ។

### ទី៣-ការអភិវឌ្ឍស្ថាប័ន :

ដើម្បីសម្រេចបានតាមគោលដៅជាយុទ្ធសាស្ត្រ នៃការកសាងរដ្ឋបាលគយមួយទំនើប, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា កំពុងបន្តអនុវត្តយ៉ាងសកម្មនូវផែនការអភិវឌ្ឍធនធាន

មនុស្ស និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមទាំងការបំពាក់មធ្យោបាយបំពេញការងារផងដែរ ។ ជាក់ស្តែង, ក្រៅពីអគាររដ្ឋបាលថ្មី, អគារសាលាជាតិគយ និង សារមន្ទីរគយ, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា បាន និង កំពុងបន្តសាងសង់អគាររដ្ឋបាល, អគារស្នាក់នៅ និង ឃ្លាំងគយ នៅតាមបណ្តាសាខាគយ និង រដ្ឋាករខេត្ត ព្រមជាមួយនឹងការសាងសង់ការិយាល័យគយ និង រដ្ឋាករ នៅមាត់ច្រកព្រំដែន ដែលសមិទ្ធផលទាំងនេះ ក៏បានចូលរួមចំណែកយ៉ាងសំខាន់ផងដែរ ដល់ការលើកកម្ពស់មុខមាត់ស្ថាប័នរាជរដ្ឋាភិបាល ដែលជាអង្គភាពជំនាញ, ឈរជើងនៅតាមព្រំដែននៃប្រទេស ។

## ទី៤-ការចូលរួមអនុវត្តវិធានការគោលនយោបាយនានារបស់រាជរដ្ឋាភិបាល :

ក្រៅពីអនុវត្តភារកិច្ចស្នូលក្នុងការប្រមូលពន្ធ និង អាករ និង ការផ្តល់កិច្ចសម្រួលពាណិជ្ជកម្ម, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ក៏ចូលរួមអនុវត្តយ៉ាងសកម្ម នូវវិធានការគោលនយោបាយនានារបស់រាជរដ្ឋាភិបាល រួមមាន : ការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធអាករដល់គម្រោងវិនិយោគនានា រួមទាំង សហគ្រាសធុនតូច និង មធ្យម ក៏ដូចជាវិធានការកែសម្រួល និង បន្ធូបន្ថយអត្រាពន្ធ និង អាករលើមុខទំនិញមួយចំនួន សំដៅគាំទ្រផលិតកម្មក្នុងស្រុក និង ទ្រទ្រង់ទីផ្សារក្នុងស្រុក, ជាពិសេស វិធានការកាត់បន្ថយ ឬ លុបអត្រាពន្ធ និង អាករលើទំនិញចាំបាច់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋទូទៅ ជាដើម ។ បន្ថែមលើនេះ, ជាការចូលរួមចំណែកនៅក្នុងការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សំដៅប្រយុទ្ធនឹងជំងឺកូវីដ-១៩, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ក៏បានបង្កើតច្រកពិសេស ដែលផ្តល់ការសម្រួលលឿន និង ឆាប់រហ័សជាអតិបរមា សម្រាប់ការនាំចូលសម្ភារៈ, បរិក្ខារ និង ទំនិញផ្សេងៗ ដែលមានមុខសញ្ញាប្រើប្រាស់ នៅក្នុងការទប់ស្កាត់, ការការពារ និង ការព្យាបាលជំងឺកូវីដ-១៩ ផងដែរ ។

- សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!
- សម្តេច, ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយស!

នាឱកាសដ៏វិសេសវិសាលនេះ, ក្នុងនាមថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ និង កតវេទិតាធម៌ ប្រកបដោយគារវភក្តីភាពដ៏ស្មោះស្ម័គ្របំផុត គោរពជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចតែងផ្តល់មគ្គុទេសក៍តម្រង់ទិស

ដ៏មុតស្រួច និង ប្រកបដោយភាពប្រាកដនិយម និង ប្រសិទ្ធភាព ដល់ការអនុវត្តការងាររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ។ ជាការពិត, យើងខ្ញុំច្បាស់ជាមិនអាចសម្រេចបានសមិទ្ធផលដ៏ត្រចះត្រចង់ និង ជាប្រវត្តិសាស្ត្រទាំងនេះបានទេ បើសិនជាពុំមានការគាំទ្រ និង ការលើកទឹកចិត្ត ប្រកបដោយព្រហ្មវិហារធម៌ និង ទសពិធធម៌ ពីសំណាក់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ។ នៅក្រោមមគ្គទេសក៍ដ៏ឧត្តុង្គ-ឧត្តមនេះ, យើងខ្ញុំទាំងអស់គ្នា ជាមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, រួមទាំង មន្ត្រីគយ និង រដ្ឋាករគ្រប់ជាន់ថ្នាក់, សូមប្តេជ្ញាអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវអភិក្រមទាំងប្រាំយ៉ាងរបស់សម្តេច គឺ : «**ឆ្លុះ កញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**» ដោយខិតខំពុះពារជម្នះរាល់ឧបសគ្គ, អភិវឌ្ឍសមត្ថភាព, ពង្រឹងភក្តីភាពវិជ្ជាជីវៈ និង អភិបាលកិច្ចល្អ ដើម្បីបុព្វហេតុសង្គមជាតិកម្ពុជា ។

ជាថ្មីម្តងទៀត, ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត គោរពជូនចំពោះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលសម្តេចបានចំណាយពេលវេលាដ៏មមាញឹក និង មានតម្លៃបំផុត, អញ្ជើញចូលរួមដោយផ្ទាល់, ជាអធិបតីដ៏ខ្ពង់ខ្ពស់, ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវអគាររដ្ឋបាលថ្មី, សាលាជាតិគយ, និង សារមន្ទីរគយ នៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា នាពេលនេះ ។

មុននឹងបញ្ចប់, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និង កោតសរសើរដោយស្មោះចំពោះគ្រប់ស្ថាប័នជាតិពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការផ្តល់កិច្ចសហការ និង ការគាំទ្រដ៏មានតម្លៃ ដល់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ។ ខ្ញុំសង្ឃឹមថា កិច្ចសហការ និង ការគាំទ្រទាំងនេះ នឹងត្រូវបានពង្រឹង និង ពង្រីកថែមទៀត ជាប់មិនដាច់ ដើម្បីបន្តអភិវឌ្ឍរដ្ឋបាលគយ និង រដ្ឋាករកម្ពុជា ឲ្យក្លាយទៅជាស្ថាប័នមួយទំនើប, ពោរពេញដោយសមត្ថភាព, សម្រាប់អនុវត្តតួនាទី និង ភារកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពជូនជាតិ ។

នៅចុងបញ្ចប់, ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធទាំងឡាយក្នុងលោក សូមប្រោះព្រំសព្ទ-សាធុការពរ, សិរីសួស្តី, ជ័យមង្គល, វិបុលសុខមហាប្រសើរ និង សេចក្តីចម្រើនគ្រប់ប្រការ ជូនដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងសម្តេច, ឯកឧត្តម, លោកជំទាវ, អ្នកឧញ៉ា, លោកឧញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយសទាំងអស់ កុំបីឃ្លៀងឃ្លាតឡើយ ។

ជាកិច្ចបន្ត, ខ្ញុំសូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី **នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាផ្តល់មតិសំណេះសំណាលទៅកាន់អង្គពិធី ។

សូមគោរពអញ្ជើញ និង សូមអរគុណ !